**នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

| | |
|---|---|
| សំណុំរឿងលេខ: | ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ |
| ភាគីដាក់ឯកសារ: | សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី |
| ដាក់ជូន: | អង្គជំនុំជម្រះសាលាដំបូង |
| ភាសាដើម: | អង់គ្លេស |
| កាលបរិច្ឆេទឯកសារ: | ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 20-Apr-2016, 14:20
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើរបស់សហមេធាវីនាំមុខអនុលោមតាមវិធាន ៨៧(៤) ទាក់ទិននឹងដើមបណ្តឹងរដ្ឋប្បវេណីដែលមានលេខសម្គាល់ 2-TCCP-243**

---

**ដាក់ដោយ៖**

**សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Marie GUIRAUD

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី

ហុង គីមសួន

គីម ម៉េងឃី

**នៅចំពោះមុខ៖**

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យូរ ឧត្តរា

ចៅក្រម Claudia FENZ

**ផ្ញើជូន៖**

Original EN: 01224179-01224183

ឡោ ជុនធី

ម៉ុច សុវណ្ណារី

ស៊ិន សុវ៉ន

សំ សុគង់

គង់ ពិសី

វ៉េន ពៅ

ទី ស្រ៊ីនណា

Laure DESFORGES
Ferdinand DJAMMEN NZEPA
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Yiqiang Y. LIU
Daniel LOSQ
Christine MARTINEAU
Lyma NGUYEN
Mahesh RAI
Nushin SARKARATI

**ការិយាល័យសហព្រះរាជអាជ្ញា៖**

ជា លាង

Nicholas KOUMJIAN

**ជនជាប់ចោទ៖**

ខៀវ សំផន

នួន ជា

**សហមេធាវីការពារក្តី៖**

សុន អរុណ

Victor KOPPE

គង់ សំអុន

Anta GUISSÉ

**សហមេធាវីប្រចាំការ៖**

ទូច វរល័ក្ស

Calvin SAUNDERS

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

Olivier BAHOUGNE
Patrick BAUDOUIN
Beini Ye

## I. សេចក្ដីផ្ដើម

1. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អ.វ.ត.ក សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ("សហមេធាវីនាំមុខ") សូមស្នើដោយគោរពដល់អង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") មេត្តាបញ្ចូលទៅក្នុងសំណុំរឿង និងទទួលយកជាភ័ស្តុតាងនូវឯកសារនៅក្នុងឧបសម្ព័ន្ធ ក នូវសៀវភៅមួយក្បាលដែលនិពន្ធដោយដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-243។

## II. ច្បាប់ជាធរមាន

2. វិធានផ្ទៃក្នុងរបស់តុលាការបានផ្ដល់ឆន្ទានុសិទ្ធិយ៉ាងទូលំទូលាយដល់អង្គជំនុំជម្រះ ក្នុងការទទួលយកឯកសារជាភ័ស្តុតាង[1] នៅពេលដែលឯកសារទាំងនោះស្របទៅនឹងលក្ខណៈវិនិច្ឆ័យនៃភាពជាប់ពាក់ព័ន្ធ ភាពជឿជាក់បាន និងយថាភាព ដែលមានចែងក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង[2]។ អង្គជំនុំជម្រះបានសម្រេចថា ភ័ស្តុតាងដែលត្រូវយកមកពិចារណាតាមវិធាន ៨៧(៣) ត្រូវតែស្របទៅនឹងបទដ្ឋាននៃភាពជាប់ពាក់ព័ន្ធ ភាពជឿជាក់បាន និងយថាភាព*តាមការវិភាគបឋម*[3]។ នៅក្នុងការសម្រេចពីភាពជឿជាក់បាន អង្គជំនុំជម្រះបានបង្ហាញថា "ទោះបីក្របខ័ណ្ឌគតិយុត្តរបស់ អ.វ.ត.ក មិនបានតម្រូវក៏ដោយ សូចនានៃភាពជឿទុកចិត្ត [...] អាចជួយដល់អង្គជំនុំជម្រះក្នុងការ

[1] វិធាន ៨៧(១) នៃវិធានផ្ទៃក្នុង វិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិសោធនកម្មលើកទី ៨ ថ្ងៃទី ៣ ខែសីហា ឆ្នាំ ២០១១ (ចែងថា "លើកលែងតែមានបទប្បញ្ញត្តិផ្សេងក្នុងវិធានផ្ទៃក្នុងនេះ រាល់ភស្តុតាងទាំងអស់ត្រូវតែទទួលយក")។

[2] វិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងចែងថា "អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធចំពោះពាក្យសុំឱ្យពិនិត្យភស្តុតាង បើយល់ឃើញថា៖ ក-មិនជាប់ពាក់ព័ន្ធ ឬ ជាការស្នើសុំជាន់គ្នា ខ-មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ គ-មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង ឃ-ច្បាប់មិនអនុញ្ញាត ឬ ង-មានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍"។

[3] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង "ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងផ្នែកខ្លះនៃឯកសារ E114, E114/1, E131/1/9, E131/6, E136 និង E158" ឯកសារ **E162** ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ កថាខណ្ឌ ២។ *សូមមើលផងដែរ* អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង "ចម្លើយតបទៅនឹងសំណើតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងរបស់សហព្រះរាជអាជ្ញាជនជាប់ចោទ នួន ជា និង ខៀវ សំផន (E236/4/1, E265, E271, E276 និង E276/1)" ឯកសារ **E276/2** ចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០១៣ (តទៅនេះហៅថា "អនុស្សរណៈស្ដីពីឯកសារថ្មីៗ") កថាខណ្ឌ ២។

វាយតម្លៃថាតើ ភស្តុតាងដែលលើកឡើងបំពេញលក្ខខណ្ឌនានាដែលមាននៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង នោះបានដែរឬទេ”[4]។

3. វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងទទួលយកភស្តុតាងថ្មីដែលមានប្រយោជន៍សម្រាប់ស្វែងរកការពិត និងស្របទៅតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង ប្រសិនបើភស្តុតាងបែបនេះមិនអាចរកបាន នៅមុនពេលចាប់ផ្តើមដំណើរការជំនុំជម្រះ ឬមិនអាចរកឃើញបន្ទាប់ពីបានបំពេញការងារដោយយកចិត្តទុកដាក់[5]។ អង្គជំនុំជម្រះនឹងពិចារណាទៅលើឯកសារនានាដែលមិនស្ថិតនៅក្នុងបញ្ជីបឋមអនុលោមតាមវិធាន ៨០(៣) នៃវិធានផ្ទៃក្នុង ដែលត្រូវបានចាត់ទុកជាភស្តុតាងថ្មីតាមវិធាន ៨៧(៤)[6]។

4. អង្គជំនុំជម្រះក៏អាចទទួលភស្តុតាងថ្មីដែលមិនស្របទៅនឹងលក្ខខណ្ឌតម្រូវនៃភាពទាន់ពេល និងភាពយកចិត្តទុកដាក់នៃវិធាន ៨៧(៤) ប្រសិនបើភស្តុតាងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងសម្ភារៈដែលមាននៅចំពោះមុខអង្គជំនុំជម្រះ ឬទៅនឹងសក្ខីកម្មរបស់សាក្សី អ្នកជំនាញ ឬដើមបណ្តឹងរដ្ឋប្បវេណីដែលនឹងមកផ្តល់នាពេលខាងមុខ និងប្រយោជន៍យុត្តិធម៌តម្រូវថាប្រភពឯកសារទាំងនោះត្រូវយកមកវាយតម្លៃរួមគ្នា[7]។

## III. ពិភាក្សា

[4] សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ **E96/7** ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ កថាខណ្ឌ ២៩។ *សូមមើល ផងដែរ* សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ស្របតាមវិធាន ៩២ ទាក់ទិននឹងសូចនាអំពីការជឿទុកចិត្តចំពោះឯកសារចំនួន ៩៧៨ ដែលជាប់ពាក់ព័ន្ធនឹងសាក្សី និងអ្នកជំនាញដែលអាចកោះហៅសម្រាប់សវនាការបីសប្តាហ៍ដំបូង ឯកសារ **E158** ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១១ កថាខណ្ឌ ៣ (ដោយរៀបរាប់បញ្ជីយ៉ាងវែងស្តីពីសូចនានៃភាពជឿជាក់បាន រួមមាន លក្ខណៈខាងក្នុង (ឧទាហរណ៍ ចំណុចសម្គាល់ផ្សេងៗ អ្នកនិពន្ធដែលមានអត្តសញ្ញាណ ភាពស៊ីសង្វាក់គ្នាខាងក្នុងខ្លឹមសារឯកសារ) និងលក្ខណៈខាងក្រៅ (ឧទាហរណ៍ បមាណីកម្ម អត្តសញ្ញាណកម្ម និងការរកឃើញ))។

[5] អនុស្សរណៈស្តីពីឯកសារថ្មីៗ កថាខណ្ឌ ៣។

[6] *ដូចយោងខាងលើ* កថាខណ្ឌ ២។

[7] *ដូចយោងខាងលើ*។ *សូមមើល ផងដែរ* សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត ឯកសារ **E190** ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ ២១។ អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង “សំណើសុំលើកទីពីររបស់លោក អៀង សារី អនុលោមតាមវិធាន ៨៧(៤) ទាក់ទងនឹងឯកសារដែលប្រើប្រាស់ក្នុងអំឡុងពេលសាកសួរដេញដោលអ្នកជំនាញ David Chandler” ឯកសារ **E172/24/5** ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១២។

5. សហមេធាវីនាំមុខលើកឡើងថា ដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-243 ត្រូវបានស្នើសុំឱ្យកោះហៅមកផ្ដល់សក្ខីកម្មដោយសហមេធាវីនាំមុខផង[8] និងសហព្រះរាជអាជ្ញាផង[9] ទៅលើប្រធានបទសវនាការស្ដីពីមន្ទីរសន្ដិសុខ ស-២១។ នៅថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ពេលស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-243 នៅថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦[10]។

6. ដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-243 បាននិពន្ធសៀវភៅមួយក្បាលមានចំណងជើងថា៖ "Survivor: The Triumph of an Ordinary Man in the Khmer Rouge Genocide"។ *ក្នុងចំណោមនោះ* សៀវភៅនេះរៀបរាប់ពីស្ថានភាពរស់នៅរបស់គាត់ក្នុងពេលជាប់ឃុំឃាំងនៅមន្ទីរ ស-២១ និងទាក់ទិននឹងសំណើសុំផ្ដល់សក្ខីកម្ម។

7. សៀវភៅនេះត្រូវបានបោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។ សៀវភៅមានជាបីភាសាដែលប្រើប្រាស់នៅតុលាការ។ ឧបសម្ព័ន្ធ ក មានព័ត៌មានលម្អិតអំពីឯកសារនេះ និងរបៀបដែលវាពាក់ព័ន្ធនឹងចំណុចនានានៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០២/០២។

8. ផ្នែកមួយចំនួននៃសៀវភៅ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងសំណើសុំឱ្យកោះហៅដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-243 មកផ្ដល់សក្ខីកម្ម។ ឧបសម្ព័ន្ធ ខ គឺជាសំណៅថតស្កែននៃសេចក្ដីដកស្រង់ចេញពីសៀវភៅ ដែលនិពន្ធដោយដើមបណ្ដឹងរដ្ឋប្បវេណី មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងសំណើសុំគាត់ឱ្យមកផ្ដល់សក្ខីកម្ម ដែលមិនទាន់មានក្នុងសំណុំរឿង។ សហមេធាវីនាំមុខលើកឡើងថា សេចក្ដីដកស្រង់ទាំងនេះមានភាពពាក់ព័ន្ធ និងអាចជឿជាក់បាន*តាមការវិភាគបឋម*។

---

[8] បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៨០ របស់សហមេធាវីនាំមុខតំណាង ដើមបណ្ដឹងរដ្ឋប្បវេណីសម្រាប់សំណុំរឿង ០០២/០២ ដោយមានឧបសម្ព័ន្ធសម្ងាត់ ឯកសារ **E305/7** ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៤។ *សូមមើល បន្ថែម* ឧបសម្ព័ន្ធ III៖ សេចក្ដីសង្ខេបដែលបានធ្វើបច្ចុប្បន្នភាពអំពីសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញ (ដែលពុំបានស្វែងរកវិធានការការពារ) ឯកសារ **E305/7.1.3** លេខរៀង ១១ ទំព័រ ១៩។

[9] បញ្ជីសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា និងសេចក្ដីសង្ខេបសម្រាប់ជំនុំជម្រះក្នុងសំណុំរឿងលេខ ០០២/០២ ឯកសារ **E305/6** ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៤។ *សូមមើល បន្ថែម* ឧបសម្ព័ន្ធ III៖ សេចក្ដីសង្ខេបអំពីសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលបានធ្វើបច្ចុប្បន្នភាពរបស់ ក.ស.ព ឯកសារ **E305/6.4** លេខរៀង ១ ទំព័រ ៣៧ (ភាសាអង់គ្លេស)។

[10] សារអេឡិចត្រូនិកពីមន្ត្រីច្បាប់ជាន់ខ្ពស់ផ្ញើជូនភាគី មានចំណងជើងថា៖ "ការកំណត់ពេលសវនាការថ្ងៃទី ១៨ ដល់ ២៨ ខែ មេសា ឆ្នាំ ២០១៦" ចុះថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៦ នៅវេលាម៉ោង ៤:០២ នាទីរសៀល។

9. សៀវភៅនេះ បោះពុម្ពផ្សាយនៅឆ្នាំ ២០១២ ហើយហេតុនេះ មិនអាចរកបានមុនពេលចាប់ផ្តើម ដំណើរការជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ បានទេ[11]។ ក៏ប៉ុន្តែ សៀវភៅនេះមិនត្រូវបានបញ្ចូល ក្នុងបញ្ជីតាមវិធាន ៨០ របស់សហមេធាវីនាំមុខទេ។

10. អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានទទួលយកសេចក្តីដកស្រង់ចេញពីសៀវភៅមួយក្បាលដែលបាន បោះពុម្ពផ្សាយ។ សៀវភៅនោះ បោះពុម្ពផ្សាយប្រហែលមួយឆ្នាំមុនដាក់សំណើតាមវិធាន ៨៧ (៤)[12]។ សហមេធាវីនាំមុខលើកឡើងថា ជាប្រយោជន៍យុត្តិធម៌ដែលថា សក្ខីកម្មផ្ទាល់ត្រូវយកមក វាយតម្លៃរួមគ្នាជាមួយខ្លឹមសារនៅក្នុងសៀវភៅ[13]។ ការទទួលយកសំណើនេះនឹងជួយស្វែងរក ការពិតបន្ថែមទៀត ដោយមិនប៉ះពាល់ដល់សិទ្ធិរបស់ភាគីក្នុងកិច្ចដំណើរការនីតិវិធី។

## IV. សំណើ

11. អនុលោមតាមសំអាងហេតុនានាដែលបានលើកឡើងខាងលើ សហមេធាវីនាំមុខសូមស្នើដោយ គោរពដល់អង្គជំនុំជម្រះសាលាដំបូង មេត្តា៖

(១) **ទទួលយក**ជាភ័ស្តុតាង និងបញ្ចូលទៅក្នុងសំណុំរឿងនូវឯកសារដែលមានក្នុងឧបសម្ព័ន្ធ ខ អនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤)។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៦ | ពេជ អង្គ<br>សហមេធាវីនាំមុខ | ភ្នំពេញ | |
| | Marie GUIRAUD<br>សហមេធាវីនាំមុខ | ភ្នំពេញ | |

[11] សេចក្តីសម្រេចលើសំណើរួមរបស់ភាគីសុំការបំភ្លឺអំពីការអនុវត្តវិធាន ៨៧(៤) (ឯកសារ E307) និងសេចក្តីជូនដំណឹងរបស់ក្រុមមេធាវីការពារក្តី នួន ជា ស្តីពីការមិនដាក់បញ្ជីភ័ស្តុតាងដែលបានធ្វើបច្ចុប្បន្នភាព (ឯកសារ E305/3) ឯកសារ **E307/1** ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៤ កថាខណ្ឌ ២។

[12] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យទទួលយកសេចក្តីដកស្រង់ចេញពីសៀវភៅដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ អនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤) ឯកសារ **E342/3** ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ កថាខណ្ឌ ៤។

[13] *ដូចយោងខាងលើ* កថាខណ្ឌ ៥។